# ការសំភាសន៍របស់ម៉ាក់យាយ ទុយ សៀម

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ ទុយ សៀម

## ការសង្ខេបប្រវត្តិរបស់ ម៉ាក់យាយ ទុយ សៀម

ម៉ាក់យាយ ទុយ សៀម មាន60អាយុឆ្នាំ នៅក្នុងឆ្នាំ2018 ម៉ាក់យាយ ទុយ សៀម មានភេទស្រី ម៉ាក់យាយ ទុយ សៀម មានទីលំនៅបច្ចុប្បន្ននៅ ភូមិទូល ឃុំមហាសាង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

កៈ ចឹងជាដំបូងខ្ញុំអរគុណម៉ាក់យាយដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ម៉ាក់យាយ ហើយការសំភាសន៍ទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់ បានស្គាល់នឹងបានដឹងពីប្រវត្តិរបស់ឪពុកម្ដាយនឹង ប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍ម៉ាក់យាយ ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ពូហើយខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់ម៉ាក់យាយយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរទេម៉ាក់យាយ?

ខៈ ចាំ!!

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍ម៉ាក់យាយខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរ ខ្ញុំបានសំភាសន៍ពូគឺនៅថ្ងៃទី26ខែ4 ឆ្នាំ2018 ហើយការសំភាសន៍នឹងត្រូវបានធ្វើឡើងនៅភូមិ?

ខៈ ភូមិទូល

កៈ ភូមិទូល ឃុំមហាសាងហីម៉ាក់យាយ?

ខៈ ឃុំមហាសាង

កៈ នៅស្រុក?

ខៈ ស្រុកភ្នំស្រួច

កៈ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ?

ខៈ ចា៎!!

កៈ ចឹងសំរាប់ម៉ាក់យាយឈ្មោះពេញរបស់ម៉ាក់យាយនឹងមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ ខ្ញុំមានឈ្មោះសៀម

កៈ ចុះត្រកូលឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ ឈ្មោះទុយ សៀម

កៈ ឈ្មោះទុយ សៀមណាម៉ាក់យាយ ចុះមានឈ្មោះហៅក្រៅទេម៉ាក់យាយ?

ខៈ អត់មាន

កៈ ចុះកាលពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះម៉ាក់យាយអីផ្សេងដែរទេ?

ខៈ អត់មានទេហៅតែប៉ុណ្ណឹងមានឈ្មោះតែមួយនឹងឯង

កៈ ចឹងអត់មានឈ្មោះហៅក្រៅផ្សេងទេណាម៉ាក់យាយ?

ខៈ អត់ទេ

កៈ ចុះម៉ាក់យាយសព្វថ្ងៃម៉ាក់យាយអាយុប៉ុន្មានដែរទៅម៉ាក់យាយ?

ខៈ ខ្ញុំអាយុ60ឆ្នាំហើយ

កៈ អាយុ60ឆ្នាំគត់ហោសម៉ាក់យាយ?

ខៈ អាយុ60ឆ្នាំគត់

កៈ ចុះម៉ាក់យាយកើតនៅថ្ងៃខែឆ្នាំណាម៉ាក់យាយចាំទេ?

ខៈ អើរអត់ចាំទេក្មួយអើយខ្ញុំភ្លេចអត់ចាំដែរ

កៈ អ៎ូ!!ចឹងម៉ាក់យាយអត់មានចាំទេណា?

ខ៖ អើរ

ក៖ អ៊ុំ!!ចុះឆ្នាំខ្មែរម៉ាក់យាយឆ្នាំអីគេដែរម៉ាក់យាយឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖ ឆ្នាំខ្មែរខ្ញុំឆ្នាំចរ

ក៖ ឆ្នាំចរណាម៉ាក់យាយណា?

ខ៖ ចាំ!!

ក៖ អូ៎!!បាទសំរាប់ម៉ាក់យាយអាយុ60ឆ្នាំគត់?

ខ៖ នឹងហើយ

ក៖ ចឹងម៉ាក់យាយកើតនៅឆ្នាំ1958ម៉ាក់យាយ?

ខ៖ ចាំ!!នឹងហើយ

ក៖ អូ៎!!បាទ ចុះម៉ាក់យាយកើតនៅណាដែរម៉ាក់យាយ?

ខ៖ ខ្ញុំកើតស្រុកកំណើតនៅនឹង

ក៖ អើរនៅភូមិអីទៅ?

ខ៖ នៅភូមិទួលនឹងតែម្តង

ក៖ អូ៎!!នៅភូមិទួល ឃុំមហាសាង?

ខ៖ ចាំ!!

ក៖ នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺណាម៉ាក់យាយ?

ខ៖ ចាំ!!

ក៖ ចុះម៉ាក់យាយមានបងប្អូនចំនួនប៉ុន្មាននាក់ដែរម៉ាក់យាយ?

ខ៖ បងប្អូនរបស់ខ្ញុំនឹងរាល់ថ្ងៃនឹង

ក៖ បាទ!!ម៉ាក់យាយរាល់ថ្ងៃនឹងហាស?

ខ៖ ស្លាប់អស់3នាក់ហើយនៅតែ3នាក់ទេ

កៈ ចឹងមានបងប្អូនចំនួន6នាក់?

ខៈ ចា៎!!នឹងហើយមាន6នាក់

កៈ ចុះម៉ាក់យាយជាកូនទីប៉ុន្មានដែរម៉ាក់យាយ?

ខៈ ខ្ញុំជាកូនទី5ទី6នឹង

កៈ អូ៎!!ពៅគេហោសម៉ាក់យាយ?

ខៈ ចា៎!!អត់ពៅគេទេអាប្អូននោះពៅគេ

កៈ អូ៎!!នោះហោសម៉ាក់យាយ
អូចុះម៉ាក់យាយអាចប្រាប់ឈ្មោះបងប្អូនរបស់ម៉ាក់យាយដែរទេ
ថាពួកគាត់មានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ បងប្អូនខ្ញុំនឹងបងគេបង្អស់នេះឈ្មោះសឹម

កៈ ចុះបន្ទាប់មកម៉ាក់យាយ?

ខៈ ឈ្មោះបឿន

កៈ នឹងទី2រឺទៅ3ហោសម៉ាក់យាយ?

ខៈ នឹងទី2

កៈ ចុះមកទី3វិញ?

ខៈ ទី3នឹងមកមើលបងខ្ញុំស្លាប់នៅជំនាន់អាពតនឹងមានឈ្មោះបន

កៈ ដល់ពេលទី4ម៉ាក់យាយ?

ខៈ មានឈ្មោះបាន

កៈ ចុះដល់ពេលទី5នឹងម៉ាក់យាយ?

ខៈ ខ្ញុំនឹងហាស

កៈ ហើយចុះអាពៅគេវិញម៉ាក់យាយ?

ខ៖ ៣៧គេនឹងឈ្មោះបូក

ក៖ អូ!!បាទ ចុះម៉ាក់យាយធ្លាប់មានចងចាំអនុស្សាវរីយ៍អីកាលពីម៉ាក់យាយនៅក្មេង
មានសាច់រឿងអីដែរថាម៉ាក់យាយចាំអត់ភ្លេចហាស
ដូចថាលេងបិទពួនលេងអីចឹងហាសម៉ាក់យាយ?

ខ៖ លេងៗៗលេងបិទពួនជាមួយបងប្អូននៅក្នុងភូមិនឹងណា

ក៖ អូ!!នឹង?

ខ៖ នឹងហើយលេងបិទពួននឹង

ក៖ ប៉ុន្តែលក្ខណះថាម៉ាក់យាយធ្លាប់លេងគប់ លេងឈូសអីជាមួយបងប្អូនទេ?

ខ៖ លេងធ្លាប់លេងដែរពីនៅក្រមុំអីនឹង

ក៖ អូ!!បាទម៉ាក់យាយ?

ខ៖ លេងបោះឈូង លេងអីនឹងលេងបោះអង្គុញអីនឹងដែរនឹងហាស

ក៖ អូ!!ប៉ុន្តែម៉ាក់យាយចូលចិត្តលេងអីជាមួយបងប្អូនរបស់ម៉ាក់យាយ?

ខ៖ លេងបងប្អូនធម្មតាលេងសើចជាមួយគ្នានឹងហាស

ក៖ អូ!!ទៅស្រែទៅអីជាមួយគ្នាហោស?

ខ៖ ទៅស្រែទៅភ្លឺអីចឹងទៅណាស់

ក៖ ប៉ុន្តែភាគច្រើនទៅស្រែនឹងទៅធ្វើអីគេទៅជាមួយបងប្អូន?

ខ៖ ចា៎!!ទៅស្រែទៅអីជាមួយបងប្អូននឹង

ក៖ ប៉ុន្តែភាគច្រើនទៅធ្វើអីគេដែរទៅ?

ខ៖ មិនធ្វើអីនឹងធ្វើតែស្រែហ្វបទេ

ក៖ ចឹងហោសម៉ាក់យាយ?

ខ៖ ចា៎!!

កៈ អូ៎!!បាទ?

ខៈ ធ្វើតែស្រែហ្នឹង

កៈ ចុះបងប្អូនរបស់ម៉ាក់យាយសព្វថ្ងៃគាត់នៅណាដែរម៉ាក់យាយឥឡូវនឹង?

ខៈ នៅភូមិអមរវត្តនោះមួយ ហើយខ្ញុំមួយ បងនៅភូមិនេះមួយនៅបីនាក់នឹង

កៈ អូ៎!!បាទម៉ាក់យាយ?

ខៈ ពីរនាក់នោះស្លាប់បាត់ហើយ

កៈ បាទ!!ម៉ាក់យាយ?

ខៈ ស្លាប់នៅជំនាន់ពលពតហោស

កៈ ចុះពួកគាត់ធ្វើអីគេដែរទៅម៉ាក់យាយ?

ខៈ ណាគេ?

កៈ និយាយបងប្អូនរបស់ម៉ាក់យាយពួកគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរ?

ខៈ គាត់ធ្វើស្រែដូចតែខ្ញុំនឹងឯង

កៈ អូ៎!!ចឹងហោសម៉ាក់យាយ?

ខៈ ធ្វើស្រែនឹង

កៈ បាទ!!ចុះឪពុករបស់ម៉ាក់យាយឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ ចាំ!!ឮឪពុករបស់ខ្ញុំហោស?

កៈ បាទ!!ម៉ាក់យាយ

ខៈ ឪពុករបស់ខ្ញុំនឹងមានឈ្មោះប៊ូ

កៈ មានឈ្មោះប៊ូ ចុះស្អីគេប៊ូទៅម៉ាក់យាយ?

ខៈ ឈ្មោះទុយ ប៊ូនឹងតែម្តងនឹង

កៈ អូ៎!!

ខ៖ តារបស់ខ្ញុំនឹងឈ្មោះទុយ

ក៖ ប៉ុន្តែឥឡូវនឹងគាត់ដូចជា?

ខ៖ គាត់ស្លាប់បាត់ហើយ

ក៖ គាត់ស្លាប់បាត់ហើយណាម៉ាក់យាយ?

ខ៖ ចាំ!!គាត់ស្លាប់បាត់ហើយនឹង

ក៖ ប៉ុន្តែគាត់កើតនៅណាដែរម៉ាក់យាយមានដឹងទេ?

ខ៖ អត់ដឹងទេក្មួយអត់ទាន់

ក៖ កើតអត់ទាន់គាត់ហោស?

ខ៖ នឹងហើយ

ក៖ ចុះម្តាយរបស់ម៉ាក់យាយវិញមានឈ្មោះអីដែរម៉ាក់យាយ?

ខ៖ ម្តាយរបស់ខ្ញុំនឹងមានឈ្មោះផុន

ក៖ ចុះមានឈ្មោះអីគេផុនទៅម៉ាក់យាយ?

ខ៖ នឹងត្រកូលខាងម៉ែរបស់ខ្ញុំនឹងខ្ញុំមិនសូវស្គាល់ដែរនឹង
គាត់បានស្លាប់អស់ហើយតាំងពីខ្ញុំនៅតូចៗម៉េស

ក៖ បាទ!!ម៉ាក់យាយ?

ខ៖ លឺគេថាឈ្មោះផេន

ក៖ អូ!!បាទម៉ាក់យាយ?

ខ៖ ឈ្មោះ ផេន ផុន

ក៖ បាទ!!ចុះសំរាប់ម៉ាក់យាយគិតថាម្តាយរបស់ម៉ាក់យាយគាត់កើតនៅណាដែរ?

ខ៖ កើតកំណើតនៅភូមិនឹងដែរតែម្តងនឹង

កៈ អូ!!ចឹងហោសម៉ាក់យាយ
ចុះដូចជាឪពុករបស់ម៉ាក់យាយគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ?

ខៈ ឪពុករបស់ខ្ញុំបើនិយាយទៅឪពុករបស់ខ្ញុំគាត់ធ្វើតែស្រែដែរនឹង

កៈ អូ!!គាត់ធ្វើស្រែណាម៉ាក់យាយ?

ខៈ ចាំ!!នឹងហើយ

កៈ ប៉ុន្តែគាត់ជាមនុស្សបែបណាដែរម៉ាក់យាយស្លូតរឺមួយក៏កាចដែរ?

ខៈ គាត់ស្លូតឪពុករបស់ខ្ញុំនឹងអត់ដែរវៃកូនទេ

កៈ អូ!!ចឹងមានន័យថាគាត់ស្លូតទេនៅក្នុងភូមិណាម៉ាក់យាយ?

ខៈ គាត់ស្លូតនឹងហើយ

កៈ អូ!!បាទ ចុះម្តាយរបស់ម៉ាក់យាយគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ?

ខៈ ម៉ែរបស់ខ្ញុំគាត់ធ្វើតែស្រែដែរនឹង

កៈ បាទ!!ចឹងម៉ាក់យាយ?

ខៈ គាត់មានដែរទៅរកស៊ីអីអត់មានទេ ធ្វើតែស្រែចិញ្ចឹមកូននឹង

កៈ អូ!!ចុះគាត់ជាមនុស្សស្លូតរឺមួយក៏កាចដែរម៉ាក់យាយ?

ខៈ ចាំ!!គាត់ស្លូតទេម៉ែឪរបស់ខ្ញុំគាត់ស្លូតៗទេ

កៈ អូ!!ពួកគាត់សុទ្ធតែស្លូតៗទេណាម៉ាក់យាយ?

ខៈ នឹងហើយ

កៈ
ចុះម៉ាក់យាយគិតថាម៉ាក់យាយមានចងចាំសាច់រឿងអីជាមួយបងប្អូនរបស់ម៉ាក់យាយដែរទេ ថាធ្លាប់បានធ្វើអីគេខ្លះជាមួយគ្នាចឹងហាស?

ខៈ ឪពុកម្តាយបើនិយាយទៅឪពុកខ្ញុំនឹងឈឺតាំងពីខ្ញុំនៅតូចដែរ

កៈ អូ!!ចុះ?

ខ៖ គាត់ឈឺហើយបងរបស់ខ្ញុំនឹងគាត់ចិញ្ចឹមប្អូនៗៗទេ

ក៖ អូ៎!!ចឹងហោសម៉ាក់យាយ?

ខ៖ នឹងហើយៗៗ

ក៖ ប៉ុន្តែបងរបស់ម៉ាក់យាយគាត់ធ្វើមេភូមិ?

ខ៖ ចា៎!!គាត់រធ្វើមេភូមិ

ក៖ អូ៎!!បាទ!!ចុះម៉ាក់យាយធ្លាប់ទៅស្រែអីជាមួយឪពុកម្តាយដែរទេ?

ខ៖ ធ្លាប់ដែរ

ក៖ ប៉ុន្តែទៅនឹងធ្វើអីគេដែរជាមួយពួកគាត់?

ខ៖ ទៅចឹងទៅទៅស្ទូង ទៅដកចឹងទៅដល់ខែច្រូតទៅទៅច្រូតទៅជាមួយគាត់ចឹងទៅ

ក៖ ទៅច្រូតកាត់អីចឹង?

ខ៖ ទៅជួយមើលគោជាមួយគាត់អីចឹងទៅ

ក៖ អូ៎!!បាទម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖ ចុះយាយតាខាងឪពុកនឹងម៉ាក់យាយមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ យាយតា យាយតាខាងឪពុករបស់ខ្ញុំនឹងយាយខ្ញុំនឹងឈ្មោះយាយហោង ហើយតារបស់ខ្ញុំនឹងឈ្មោះងិន

ក៖ អូ៎!!នឹងខាងឪពុក?

ខ៖ នឹងខាងឪពុក

ក៖ ចុះពួកគាត់កើតនៅណាដែរម៉ាក់យាយមានដឹងទេ?

ខ៖ គាត់កើតនៅស្រុកនឹងទាំងអស់នឹងតែម្តង

ក៖ អូ៎!!ចុះយាយតាខាងម្តាយវិញម៉ាក់យាយ?

ខ៖ យាយតាខាងម្ដាយយាយរបស់ខ្ញុំខាងម្ដាយនឹងមានឈ្មោះហ៊ុន ឈ្មោះយាយហ៊ុន

ក៖ ចុះតាវិញម៉ាក់យាយ?

ខ៖ តានឹងខ្ញុំអត់សូវស្គាល់ដែរនឹងគេហៅតាសេកៗៗនឹង

ក៖ ចុះគាត់កើតនៅណាម៉ាក់យាយមានដឹងទេ?

ខ៖ គាត់កើតសុទ្ធតែស្រុកកំណើតនៅនឹងទេ

ក៖ អូ៎!!ចឹងពួកគាត់សុទ្ធតែកើតនៅនឹងទាំងអស់គ្នាហោស?

ខ៖ នឹងហើយ

ក៖ ចុះម៉ាក់យាយគិតថាម៉ាក់យាយមករស់នៅនឹងយូរនៅម៉ាក់យាយ?

ខ៖ ខ្ញុំនៅនឹងតាំងពីខ្ញុំកើតដឹងក្ដីមកនៅស្រុកនឹងរហូត

ក៖ អូ៎!!ចឹងមានន័យថាយូរហើយណាម៉ាក់យាយ?

ខ៖ យូរដែរហើយស្រុកកំណើតនៅនឹងអត់ដែរទៅណាទេ

ក៖ អូ៎!!បាទម៉ាក់យាយ?

ខ៖ បើឃ្លាតនឹងឃ្លាតពេលជំនាន់ពលពត

ក៖ អូ៎!!នៅជំនាន់ពលពតហោសម៉ាក់យាយ?

ខ៖ គេភៀសយើងអោយទៅនៅលិចទៅ

ក៖
ចុះម៉ាក់យាយគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះម៉ាក់យាយធ្លាប់មានជួបបញ្ហាអីគេខ្លះដែរទៅ?

ខ៖ អត់ដែរនឹងហាសអត់ដែរជួបបញ្ហាអីទេ

ក៖ អូ៎!!អត់ទេហោស?

ខ៖ នឹងហើយបើជួបនឹងជួបបញ្ហាពេលនៅជំនាន់ពលពតទេប៉ុណ្ណឹង

កៈ អូ៎!!បាទម៉ាក់យាយ?

ខៈ ហើយពីនឹងអត់ដែរមានអីទេ

កៈ អូ៎!!បាទម៉ាក់យាយ
ចុះម៉ាក់យាយគិតថាម៉ាក់យាយធ្លាប់មានកូនចៅណាដែរទៅរស់នៅក្រៅប្រទេសដែរទេម៉ាក់យាយ?

ខៈ កូនរបស់ខ្ញុំហោសកូនខ្ញុំទៅនៅថៃពីរនាក់ដែរ

កៈ អូ៎!!គាត់ធ្វើអីគេដែរនៅថៃហាសម៉ាក់យាយ?

ខៈ គាត់ទៅនៅក្នុងហាងលក់គុយទាវ

កៈ អូ៎!!គាត់ទៅធ្វើការងារអោយគេហោស?

ខៈ ចា៎!!

កៈ ប៉ុន្តែដូចជាស្វាមីរបស់ម៉ាក់យាយនឹងមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ គាត់ឈ្មោះនី

កៈ ប៉ុន្តែដូចជាគាត់ឥឡូវនឹងគាត់?

ខៈ គាត់ស្លាប់បាត់ហើយ

កៈ ចឹងគាត់ស្លាប់ហើយណា?

ខៈ នឹងហើយ

កៈ ប៉ុន្តែម៉ាក់យាយមានចងចាំថាម៉ាក់យាយការនៅថ្ងៃខែឆ្នាំណាដែរទេ?

ខៈ ខ្ញុំការនឹងអត់ចាំដែរអូនអើយកាលណុងខ្ញុំការនៅជំនាន់នៅពលពតនៅឡើយទេនៅខ្មែរក្រហមនៅ ឡើយទេ

កៈ បាទ!!ម៉ាក់យាយ?

ខៈ ពីព្រោះអីខ្មែរក្រហមវាមិនទាន់ប្រមូលអស់នៅក្របខ័ណ្ឌហាសក្មួយ

កៈ បាទ!!ម៉ាក់យាយបាទ?

ខ៖ វានៅមួយកន្លែងៗៗនៅឡើយទេប៉ុណ្ណឹង

ក៖ បាទ!!ចុះម៉ាក់យាយគិតថាដូចជានៅពេលដែរម៉ាក់យាយរៀបអាពាហ៍ជាមួយតានឹងគិតថាម៉ាក់យាយជាអ្នករៀបចំដោយខ្លួនឯងរឺមួយឪពុកម្ដាយជាអ្នករៀបចំអោយពេលណុង?

ខ៖ បងខ្ញុំបង្កើតនឹង

ក៖ អូ!!បងជាអ្នករៀបចំអោយហោសម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖
អូ!!បាទចុះម៉ាក់យាយគិតថាដូចជាមានជាជំនូនទេនៅពេលដែរតាចូលស្ដីដណ្ដឹងម៉ាក់យាយហាស?

ខ៖ មានជំនាន់ណុងមាន

ក៖ ប៉ុន្តែពេលណុងជាស្អីដែរទៅម៉ាក់យាយ?

ខ៖ មានស្អីយើងកាលនៅជំនាន់ណុងមានតែនំអន្សមចេកតែប៉ុណ្ណឹង

ក៖ អូ!!នុំអន្សមចេកហោសម៉ាក់យាយ?

ខ៖ នឹងហើយវាមិនសំបូរផ្លែឈើផ្លែព្រៃដូចឥឡូវនឹងណាអត់

ក៖ អូ!!បាទម៉ាក់យាយ?

ខ៖ ខ្ញុំការតាំងពីជំនាន់ណុងមកនឹងថ្លៃផ្ទះយើងបីពាន់ខ្មែរនឹង

ក៖ អូ!!បីពាន់លុយខ្មែរហោស?

ខ៖ នឹងហើយបីពាន់លុយខ្មែរនឹង

ក៖ អូ!!ចុះម៉ាក់យាយគិតថាពេលណុងតាស្រលាញ់ម៉ាក់យាយអស់ប៉ុន្មានឆ្នាំដែរបានជាតាចូលស្ដីដណ្ដឹងម៉ាក់យាយ?

ខ៖ គាត់ស្រលាញ់ខ្ញុំអស់ជាងមួយឆ្នាំដែរ

កៈ អូ៎!!ជាងមួយឆ្នាំហោស?

ខៈ នឹងហើយ

កៈ ប៉ុន្តែដូចជាម៉ាក់យាយគិតថាតាធ្វើអីគេដែរទៅសំរាប់ចូលស្ដីដណ្ដឹងម៉ាក់យាយ?

ខៈ តារបស់ខ្ញុំនឹងគាត់ធ្វើជាទាហ៊ាន

កៈ អូ៎!!គាត់ធ្វើជាទាហ៊ានហោស?

ខៈ ចាំ!!

កៈ អូ៎!!ឡូយដែរតើ!

ខៈ គាត់ធ្វើជាទាហ៊ាន ធ្វើទាហ៊ានដល់ទៅសៀមរាបអីនឹង

កៈ ចុះម៉ាក់យាយគិតថាម៉ាក់យាយចេះអាន
រឺមួយក៏ចេះសរសេរអក្សរបានល្អប៉ុណ្ណាដែរទៅម៉ាក់យាយ?

ខៈ ខ្ញុំអត់ចេះតែម្ដងអក្សរខ្ញុំអត់បានរៀននឹងគេនឹងហើយ

កៈ អូ៎!!ចុះម៉ាក់យាយគិតថាម៉ាក់យាយមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេម៉ាក់យាយ?

ខៈ អើរ

កៈ ប៉ុន្តែយាយមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេ?

ខៈ អត់ចេះផង

កៈ ដូចជាភាសាថៃ នឹងភាសាវៀតណាមអី?

ខៈ ភាសាថៃអត់ចេះ នឹងភាសាវៀតណាមអត់ចេះផងខ្ញុំអត់ចេះទេអត់ដែររៀនទេ

កៈ អូ៎!!ចុះម៉ាក់យាយធ្លាប់មានមិត្តភក្តិដែរស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាដែរទេ
តាំងពីក្មេងរហូតមកដល់ឥឡូវចឹងហាស?

ខៈ អត់ទេមានតែអ្នកនៅក្នុងស្រុកភូមិនឹងទេ

កៈ អូ៎!!ចឹងមានតែមិត្តភក្តិបងប្អូននៅក្នុងភូមិទេណាមីង?

ខ៖ នឹងហើយចាំ!!

ក៖ ចុះម៉ាក់យាយគិតថាម៉ាក់យាយធ្លាប់ធ្វើអីគេដែរជាមួយពួកគាត់ទេ?

ខ៖ អត់មានធ្វើអីទេលេងសើច អង្គុយលេងសើចជាមួយគ្នានៅក្នុងភូមិនឹងហាស

ក៖ អូ៎!!អង្គុយចចែកគ្នាលេងហោស?

ខ៖ ចាំ!!អង្គុយចចែកគ្នាលេងនឹង

ក៖ បាទ!!ម៉ាក់យាយចុះសំរាប់ម៉ាក់យាយគិតថាដូចជាតាំងពីក្មេងរហូតមកដល់ពេលនេះ ម៉ាក់យាយធ្លាប់ធ្វើការងារអីគេខ្លះដែរនៅក្នុងជីវិតរបស់ម៉ាក់យាយ?

ខ៖ ខ្ញុំនៅក្នុងជីវិតរបស់ខ្ញុំនឹងខ្ញុំភ្ជួររាស់ខ្លួនតែម្តងនឹង ខ្ញុំភ្ជួររាស់ខ្លួននឹង

ក៖ ចឹងមានន័យថាម៉ាក់យាយធ្វើស្រែរហូតនឹង?

ខ៖ ខ្ញុំធ្វើស្រែរហូត

ក៖ ចឹងម៉ាក់យាយអត់ដែរលក់ដូរអីទេ?

ខ៖ អត់ខ្ញុំអត់ដែរលក់ដូរអីទេ

ក៖ ប៉ុន្តែម៉ាក់យាយធ្លាប់ចិញ្ចឹមសត្វ ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ ចិញ្ចឹមទាអីទេម៉ាក់យាយ?

ខ៖ ធ្លាប់កាលពីមុនខ្ញុំធ្លាប់ចិញ្ចឹមសត្វ ចិញ្ចឹមមាន់ ចិញ្ចឹមជ្រូកអីដែរនឹង

ក៖ ប៉ុន្តែចិញ្ចឹមលក្ខណៈជាកសិដ្ឋាន រឺមួយក៏ចិញ្ចឹមជាលក្ខណៈខ្នាតធំដែរម៉ាក់យាយ?

ខ៖ អត់ទេចិញ្ចឹមជាលក្ខណៈជាគ្រួសារទេចិញ្ចឹមជាលក្ខណៈមួយពីរអីទេនឹងហាស

ក៖ អូ៎!!ចឹងហោសម៉ាក់យាយ?

ខ៖ នឹងហើយចឹង

ក៖ ចុះម៉ាក់យាយគិតថាដូចជាតាំងពីក្មេងរហូតមកដល់ពេលនេះ នៅក្នុងជីវិតរបស់ម៉ាក់យាយមានការផ្លាស់ប្តូរអីគេខ្លះដែរទៅម៉ាក់យាយ?

ខ៖ កាលនៅពីសង្គមមានតែមួយតែតឡូវនឹងគ្រាន់តែថាវារីកចំរើនខ្លះ គ្រាន់បានកូនដើររកស៊ីអីចឹងណាស់ក្មួយ

កៈ អូ៎!!បាទម៉ាក់យាយត្រូវ?

ខៈ នឹងហើយចឹង

កៈ ចុះទាំងសុខភាព នឹងជីវភាពអីនឹងឥឡូវយ៉ាងម៉េចដែរ?

ខៈ សុខភាពនឹងពេលណាដែរអត់ស្រណុកអីចឹងក៏អត់ដែរ
ជីវភាពនឹងវាអត់អីទេក្មួយទោះបីជាមានការ ខ្វះខាតតិចតួចនឹងក៏វាមិនអីដែរ

កៈ អូ៎!!បាទម៉ាក់យាយ?

ខៈ នឹងហើយ

កៈ ចុះសំរាប់ម៉ាក់យាយគិតថាម៉ាក់យាយចូលចិត្តពិសារម្ហូបអីគេដែរ
តាំងពីក្មេងរហូតមកដល់ឥឡូវហាសម៉ាក់យាយ?

ខៈ
ពីក្មេងមកនឹងបើនិយាយទៅយើងហូបរឿងតែរកក្តាមរកខ្យងអីមានម្ហូបស្រែនឹងហាសក្មួយ

កៈ អូ៎!!ចឹងហោសម៉ាក់យាយ?

ខៈ ឥឡូវនឹងមានតែទិញគេនឹងឯង

កៈ ប៉ុន្តែម្ហូបដែរម៉ាក់យាយចូលចិត្តនឹងក្តាម ខ្យងអីនឹង

ខៈ នឹងហើយ

កៈ អូ៎!!ភាគច្រើននឹងគេយកទៅធ្វើអីគេដែរម៉ាក់យាយ?

ខៈ ចាំ?

កៈ ភាគច្រើននឹងគេយកទៅធ្វើអីគេដែរក្តាម ខ្យងនឹង?

ខៈ យកមកហូបនឹង

កៈ ប៉ុន្តែយកមក?

ខៈ ស្លចឹងទៅ យកមកស្ងោរចឹងទៅខ្យង

ក៖ អ៎ូ!!បាទម៉ាក់យាយ
ចុះម៉ាក់យាយគិតថាតាំងពីក្មេងនឹងម៉ាក់យាយចូលចិត្តលេងល្បែងប្រជាប្រិយ៍អី
ដែរម៉ាក់យាយ?

ខ៖ ចាំ!!ខ្ញុំចូលចិត្តលេងដែរនឹងលេងទាញព្រាតអីដែរនឹង

ក៖ មានលាក់កន្សែង បោះអង្គុញអីដែរ?

ខ៖ មានលាក់កន្សែង បោះអង្គុញអីដែរនឹងធ្លាប់លេង

ក៖ បាទ!!ម៉ាក់យាយ
ចុះម៉ាក់យាយគិតថាមានល្បែងអីប្លែកដែរម៉ាក់យាយគិតថាពីសង្គមលេង
ហើយឥឡូវអត់លេងហាសម៉ាក់យាយ?

ខ៖ អ៎ូ!!ហើរៗៗ

ក៖
គិតថាកាលពីក្មេងគេលេងហើយឥឡូវនឹងគេអត់លេងហើយគេបានបបំបាត់ចោលហាស

ខ៖ មានចាំខ្លះនឹងអត់ខ្លះដែរ

ក៖ អ៎ូ!!បាទម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖ ចុះម៉ាក់យាយចេះច្រៀងដែរទេម៉ាក់យាយ?

ខ៖ ខ្ញុំអត់ចេះទេ

ក៖ អ៎ូ!!ខ្ញុំស្មានតែម៉ាក់យាយចេះច្រៀង?

ខ៖ អត់មានចេះទេ

ក៖ ប៉ុន្តែម៉ាក់យាយចូលចិត្តស្តាប់បទចំរៀងទេ?

ខ៖ ចេះ

ក៖ ប៉ុន្តែម៉ាក់យាយចូលចិត្តស្តាប់អីគេដែរភាគច្រើន?

ខ៖ ខ្ញុំហោសបទទាល់តែរៀងពិរោះដែរនឹងបានស្តាប់

ក៖ អូ៎!!ចឹងប៉ុន្តែម៉ាក់យាយចូលចិត្តស្តាប់ធិមស្តាប់អីដែរទេ?

ខ៖ ខ្ញុំចូលចិត្តស្តាប់ដែរតើ!!

ក៖ អូ៎!!បាទម៉ាក់យាយ?

ខ៖ នឹងហើយស្តាប់ធិមអារ្យអីនឹង

ក៖ បាទ!!ម៉ាក់យាយបាទ?

ខ៖ ស្តាប់លោកទេសលោកអីនឹង

ក៖ ចុះម៉ាក់យាយគិតថាមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់ម៉ាក់យាយ ចុះលេងឧបករណ៍ភ្លេងដែរទេម៉ាក់យាយ?

ខ៖ អត់មានផង

ក៖ បងប្អូណជីដូនមួយអីក៏អត់មានដែរណា?

ខ៖ អត់មាន

ក៖ ចុះផ្ទះរបស់ម៉ាក់យាយមានលក្ខណះបែបណាម៉ាក់យាយតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ ផ្ទះរបស់ខ្ញុំពីក្មេងកាលពីជំនាន់ម៉ែឪរបស់ខ្ញុំហាសនៅវាផ្ទះស្លឹកទេក្មួយអើយកាលនៅជំនាន់ណុង

ក៖ អូ៎!!

ខ៖ ចាំ!!

ក៖ ប៉ុន្តែកាលពីជំនាន់ណុងនរណាគេជាអ្នកសាងសងផ្ទះមួយណុងដែរម៉ាក់យាយ?

ខ៖ ម្តាយរបស់ខ្ញុំហើយនឹងឪពុករបស់ខ្ញុំ

កះ ចុះគាត់ចេះធ្វើផ្ទះអត់?

ខះ គាត់ចេះដែរតើ!!

កះ អូ៎!!គាត់ចេះមកពីនរណាគេដែរ?

ខះ ដឹងគាត់ចេះមកពីណាគាត់ចេះមកពីម៉ែឪរបស់គាត់ទេដឹង

កះ អូ៎!!ល្អម៉ាក់យាយ?

ខះ នឹងហើយ

កះ ចឹងមានន័យថាគាត់ធ្វើផ្ទះធ្វើអីនឹងគាត់ធ្វើដោយខ្លួនឯង?

ខះ គាត់ធ្វើដោយខ្លួនឯងនឹង

កះ អូ៎!!ឡូយ
ចុះម៉ាក់យាយគិតថាដូចជាឪពុកម្តាយរបស់ម៉ាក់យាយធ្លាប់មានបង្រៀនពីជំនាញអីទៅម៉ាក់យាយដែរទេ?

ខះ ឪពុកម្តាយរបស់ខ្ញុំនឹងតាំងពីខ្ញុំដឹងក្តីមកនឹងខ្ញុំជំនាញដែររឿងខ្ញុំធ្វើស្រែនឹង
ខ្ញុំភ្ជួរខ្ញុំរាស់ដកស្ទូងខ្លួនឯង ដូចផ្ទះសំបែងអីដូចជារោងគោអីនឹងខ្ញុំធ្វើខ្លួនឯងកើត

កះ អូ៎!!ម៉ាក់យាយចេះធ្វើហោស?

ខះ ចាំ!!ខ្ញុំចេះធ្វើ

កះ អូ៎!!ឡូយម៉េសម៉ាក់យាយចេះមកពីនរណាគេ?

ខះ ខ្ញុំចេះមកពីឪពុករបស់ខ្ញុំ

កះ ម៉ាក់យាយគិតថាជំនាញអីដែរម៉ាក់យាយគិតថាម៉ាក់ចេះស្ទាត់ជំនាញតែម្តង?

ខះ អត់ទេក្មួយយើងមានជំនាញតែរបរធ្វើស្រែនឹងទេ

កះ អូ៎!!មួយនឹងជាជំនាញរបស់ម៉ាក់យាយដែរម៉ាក់យាយចេះស្ទាត់?

ខះ ចាំ!!

កៈ អូ!!បាទចុះម៉ាក់យាយអាចប្រាប់ពីការលំបាករបស់ម៉ាក់យាយបានទេ ថាម៉ាក់យាយមានការលំបាកអីគេខ្លះដែរចឹងហាសម៉ាក់យាយ?

ខៈ លំបាកជីវិតរបស់ខ្ញុំមកបងប្អូនរបស់ខ្ញុំមានបងប្អូន5-6នាក់នឹងឈឺ ហើយឪពុកនឹងឈឺបងរបស់ខ្ញុំនឹងជាអ្នកចិញ្ចឹម

កៈ ចុះម៉ាក់យាយគិតថាកាលពីក្មេងនឹងម៉ាក់យាយធ្លាប់មានការលំបាកអីគេខ្លះដែរទៅ?

ខៈ លំបាកណាស់រឿងឪពុកឈឺនឹងតែម្ដងនឹង

កៈ អូ!!បាទម៉ាក់យាយ?

ខៈ អត់មានលុយអត់កាក់ថៃនឹង

កៈ ចុះចឹងម៉ាក់យាយគិតថាម៉ាក់យាយធ្វើអីគេដែរទៅ ទៅលក់ដូរអីចឹងទៅ?

ខៈ កាលពីជំនាន់ណុងអត់មានបានលក់ដូរអីនឹងគេអត់

កៈ ចឹងយើងធ្វើអីគេដែរទៅពេលណុង?

ខៈ ចេញតែរកស៊ីធ្វើស្រែចិញ្ចឹមបងចិញ្ចឹមប្អូនចឹងទៅ

កៈ អូ!!បាទម៉ាក់យាយ?

ខៈ ដល់ពេលដែរដល់ខែធ្វើស្រែនឹងធ្វើស្រែចិញ្ចឹមបងប្អូនចឹងទៅ

កៈ បាទ!!ម៉ាក់យាយ?

ខៈ ធ្វើស្រែធ្វើចំការចឹងទៅ ដាំបន្លែបន្លុកចឹងទៅ

កៈ បាទ!!ម៉ាក់យាយ ចុះម៉ាក់យាយគិតថាកាលពីជំនាន់លុនណុលនឹងម៉ាក់យាយនៅក្មេងមែនទេម៉ាក់យាយ?

ខៈ ខ្ញុំនៅតូចពេលណុងខ្ញុំនៅតូចនឹង

កៈ ប៉ុន្តែពេលណុងគេមានសង្គ្រាមហើយមែនទេម៉ាក់យាយ?

ខៈ គេមានសង្គ្រាមហើយ

កៈ ប៉ុន្តែពេលណុងមានប៉ះពាល់អីដល់ខាងយើងដែរទេម៉ាក់យាយ?

ខ៖ វាប៉ះពាល់ខ្មៀតចេញពីស្រុកដែរនឹងក្មួយ

ក៖ អ៎ូ!!ពេលណុងទៅណាដែរទៅម៉ាក់យាយ?

ខ៖ រត់ទៅនៅស្រុកគេរត់ទៅនៅផ្សារវិញ

ក៖ ប៉ុន្តែមិនមែនជំនាន់ពលពតទេមែនទេម៉ាក់យាយ ជំនាន់លុនណុលនឹង?

ខ៖ អត់បានរត់ទៅនៅផ្សារតែម្តង

ក៖ អ៎ូ!!ម៉ាក់យាយ?

ខ៖ ទៅនៅវត្តចំណាយើងនឹង

ក៖ បាទ!!ម៉ាក់យាយបាទ?

ខ៖ ចុះមានស្គាល់វត្តចំណាអត់?

ក៖ ខ្ញុំអត់ស្គាល់ផង

ខ៖ វត្តចំណាយើងនៅផ្សារនៅអមផ្សារនឹង

ក៖ អ៎ូ!!បាទៗៗ ចុះហេតុអីបានជាភៀសទៅនៅណុងដែរម៉ាក់យាយ?

ខ៖ ខ្មែរក្រហមចាប់យកទៅក្រៅ

ក៖ អ៎ូ!!ហើយបានចូលជំនាន់ពលពតណាម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖ ចុះនៅពេលដែរជំនាន់ពលពតនឹងពេលណុងម៉ាក់យាយគិតថាម៉ាក់យាយនៅណាដែរ?

ខ៖ ជំនាន់ពលពតនឹងខ្ញុំនៅតូចខ្ញុំចេះទៅនៅព្រែកញ្ញៅ

ក៖ នៅព្រែកញ្ញៅហោសម៉ាក់យាយ?

ខ៖ ចា៎!!ខ្ញុំទៅនៅខាងព្រែកញ្ញៅ

ក៖ ប៉ុន្តែម៉ាក់យាយ?

ខ៖ នៅកងចល័ត

កៈ ប៉ុន្តែនៅព្រៃកញ្ចៅនឹងម៉ាក់យាយទៅធ្វើអីគេដែរទៅនៅណុង?

ខៈ ខ្ញុំទៅធ្វើស្រែ ខ្ញុំទៅធ្វើស្រែប្រាំងស្រូវប្រាំងស្រូវអីដែរចឹង

កៈ អូ៎!!បាទ?

ខៈ ដកស្ទូងអីដែរចឹងនឹង

កៈ ចុះម៉ាក់យាយគិតថាម៉ាក់យាយទៅធ្វើស្រែប្រាំងធ្វើអីនឹងណុងនឹង
ដូចជាម៉ាក់យាយទៅម្នាក់ឯង រឺមួយម៉ាក់យាយទៅជាក្រុមគ្រួសារ?

ខៈ ទៅទាំងក្រុមទាំងកងនឹងតែម្តង អត់ទេទៅតែខ្ញុំទេ

កៈ អូ៎!!គ្រួសារនឹងនៅផ្សេង?

ខៈ សំរាប់គ្រួសារនឹងនៅសហករ

កៈ អូ៎!!បាទម៉ាក់យាយ?

ខៈ នឹងហើយ

កៈ ប៉ុន្តែពេលណុងម៉ាក់យាយអាយុប៉ុន្មានដែរហើយ?

ខៈ កាលណុងហោសខ្ញុំនៅអាយុប៉ុន្មានអណ្តប់នៅឡើយ

កៈ ប៉ុន្តែម៉ាក់យាយពេលណុងម៉ាក់យាយចូលកងនារីហើយហី?

ខៈ នៅកងកុមារ

កៈ អូ៎!!នៅកងកុមារ?

ខៈ ចាំ!!

កៈ អូ៎!!បាទចុះដូចជាម្ហូបអាហារ របរអាហារអីយ៉ាងម៉េចដែរម៉ាក់យាយពេលណុង?

ខៈ ម្ហូបអាហារបើនិយាយទៅម្ហូបនឹងវាអត់ខ្វះទេនៅណុងនៅជំនាន់ណុងណាស់ក្មួយ

កៈ បាទ!!ម៉ាក់យាយ?

ខៈ ជំនាន់ណុងវាអត់ខ្វះទេណាស់ក្មួយវាគ្រាន់តែខ្វះបាយទឹកបន្តិច

កៈ អ្វូ!!បាទម៉ាក់យាយ?

ខៈ រឿងម្ហូបអីនឹងអត់ខ្វះទេ

កៈ ចុះប៉ុន្តែគេអោយម៉ាក់យាយទៅតែណុងតើហីគេអត់អោយទៅណាទៀតណាហី?

ខៈ អត់អត់អោយខ្ញុំទៅទេនៅតែមាត់ទន្លេនឹងតែម្តង

កៈ នៅរហូតទាល់តែគ្រប់3ឆ្នាំនឹងតែម្តង?

ខៈ នៅរហូតទាល់តែពលពតចូលបានខ្ញុំរត់ចេញមក

កៈ អ្វូ!!បាទម៉ាក់យាយ?

ខៈ នឹងហើយ

កៈ
ចុះម៉ាក់យាយគិតថាកាលពីជំនាន់ពលពតនឹងក្រុមគ្រួសាររបស់ម៉ាក់យាយនឹងគេអោយភៀស ទៅណាដែរទៅ?

ខៈ ភៀសនៅជិតៗៗនឹងដែរក្មួយនៅភូមិយើងក្រាំថ្លែងនេះ

កៈ បាទ!!

ខៈ នៅចុងភូមិចុងក្រូចនេះ

កៈ ប៉ុន្តែពួកគាត់ភាគច្រើននឹងបងប្អូនរបស់ម៉ាក់យាយក៏បែកគ្នាអស់ដែរ?

ខៈ បែកគ្នាអស់

កៈ ប៉ុន្តែភាគច្រើននឹងគេអោយពួកគាត់នឹងធ្វើអីគេទៅ?

ខៈ ធ្វើលើកទំនុបជីកប្រឡាយចឹងទៅ ធ្វើស្រែទៅធ្វើចំការខ្លះចឹងទៅ

កៈ អ្វូ!!បាទម៉ាក់យាយ?

ខៈ នឹងហើយ

កៈ ចុះម៉ាក់យាយគិតថាដូចជាដល់ពេលដែរដាច់ជំនាន់ពលពតហើយ
យើងចូលជំនាន់អីគេមួយទៀតដែរម៉ាក់យាយ
អើរជំនាន់គេចាប់យកទៅធ្វើជាទាហ៊ានហីម៉ាក់យាយ?

ខៈ នឹងហើយចូលមកចាប់ជំនានពលពតនឹងចូលមកជំនាន់

កៈ នៅជំនាន់ប៉ែតជាងហីម៉ាក់យាយ?

ខៈ ចាំ!!នៅជំនាន់ប៉ែតជាងនឹងហើយ

កៈ ចុះនៅជំនាន់ប៉ែតជាងនឹងម៉ាក់យាយមានការលំបាកអីគេដែរទៅម៉ាក់យាយ
ដោយសារតែពេលណុងគេមិនទាន់ចាយលុយទេណាម៉ាក់យាយ?

ខៈ លំបាកជំនាន់ណុងអត់មានចាយលុយពិបាកមែន

កៈ អូ៎!!ហើយចុះពេលណុងម៉ាក់យាយមានការលំបាកអីគេទៅ
ហើយក្រុមគ្រួសាររបស់ម៉ាក់យាយនឹងមានការលំបាកអីគេខ្លះដែរទៅពេលណុងហោស?

ខៈ ខ្ញុំលំបាកណាស់ក្មួយអោយដូចថាខ្ញុំធ្វើស្រែធ្វើភ្លឺអីចឹងវាអត់សូវបានអត់អីចឹងទៅ
ហើយយើងចេះតែរកនេះរកនោះបានហូបខ្លះអីខ្លះចឹងទៅណាស់

កៈ អូ៎!!បាទម៉ាក់យាយ?

ខៈ នឹងហើយ

កៈ ប៉ុន្តែពេលណុងម៉ាក់យាយជួបជុំក្រុមគ្រួសារវិញហើយណាម៉ាក់យាយ?

ខៈ ពេលណុងជួបជុំហើយ

កៈ
ចុះយើងធ្វើម៉េចបានយើងដឹងថាយើងជួបជុំដោយសារតែកាលពីជំនាន់ណុងគេអត់មានទូរស័ព្ទ នឹងអត់មានអីសំរាប់ទាក់ទងគ្នាផងនឹងគេអត់មានអីប្រើផងនឹង?

ខៈ យើងចេះតែបែកបងបែកប្អូនយូរពេកចឹងទៅចេះតែមករកគ្នាចឹងទៅ

កៈ មករកគ្នាដោយរបៀបម៉េចទៅដោយសារតែដីធំចង់ងាប់ហើយនឹង?

ខ៖
យើងនឹកឃើញចេះតែមករកគ្នាចឹងទៅចេះតែដើររកគ្នាចឹងទៅមករកទៅចេះតែលឺដំណឹង
គេប្រាប់នេះនៅនឹងចេះតែមករកទៅជួបគ្នាចឹងទៅ

ក៖ អូ៎!!បាទ?

ខ៖ ហើយបានឃើញទៅ

ក៖
អូ៎!!បាទម៉ាក់យាយចុះសំរាប់រហូតដល់ឆ្នាំកៅជាងដែរដល់ស្រុកខ្មែរមានសន្តិភាពហើយបា
ន ម៉ាកើយាយស្រួលធូរមែនទេ?

ខ៖ ចា៎!!បានធូរឥឡូវនឹងគ្រាន់បានធូរ

ក៖ ចុះពេលណាដែរម៉ាក់យាយគិតថាម៉ាក់យាយធូរស្រួលហើយ?

ខ៖ វាមិនបានស្រួលមែនទែមណាវានៅខ្វះខាតនៅឡើយដែរនឹង

ក៖ អូ៎!!ប៉ុន្តែម៉ាក់យាយគិតថាឥឡូវនឹងយ៉ាងម៉េចដែរម៉ាក់យាយ?

ខ៖ ឥឡូវនឹងអត់អីទេ

ក៖ ឥឡូវនឹងវារៀងធូរហើយណាបានកូនចៅអី?

ខ៖ ឥឡូវនឹងបានកូនចៅអីបានធ្វើការធ្វើងារអីចឹងទៅណាស់

ក៖ បាទ!!ម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖
ចុះម៉ាក់យាយគិតដូចជាម៉ាក់យាយឆ្លងកាត់នឹងឧបសគ្គនឹងដោយរបៀបណាដែរទៅម៉ាក់
យាយ?

ខ៖ អូ៎!!ខ្ញុំឆ្លងកាត់នៅជំនាន់ពលពតនឹងហាសឆ្លងកាត់បីសស្លាប់បីសរស់ហើយនឹង

ក៖ អូ៎!!ចឹងហោសម៉ាក់យាយណា?

ខ៖ ពីព្រោះអីខ្ញុំមកពីជំនាន់ណុងយួនវាចូល
យួនចូលមកហើយខ្ញុំនៅក្រោមគ្រាប់គេផ្លោងទៅលើ មានណាវាធ្លាប់នៅជិតយើងក្រាបនឹង

ក៖ បាទ!!ម៉ាក់យាយបាទ?

ខ៖ ពេលណា(ស្តាប់អត់បាន)យើងដើរនៅក្រោមកគ្រាប់ចឹងទៅ

ក៖ អូ៎!!ចឹងហោស?

ខ៖ នឹងហើយដើរតាំងយប់ចឹងទៅស្តាយមុងភួយខោអាវ
សាក់កាដូអីមករកបងមករកប្អូនអីនឹង

ក៖ ប៉ុន្តែកាលពីជំនាន់ណុងនៅជំនាន់ណាដែរម៉ាក់យាយ?

ខ៖ ជំនាន់ណុងនៅជំនាន់ពលពត

ក៖ ជំនាន់លុនណុល?

ខ៖ អត់ទេ

ក៖ ជំនាន់ពលពតដែរហោស?

ខ៖ អត់មានជំនាន់លុនណុលអីទេជំនាន់ពលពតជំនាន់យួនចូលនឹង

ក៖ អូ៎!!បាទ?

ខ៖ នឹងហើយ

ក៖
ចុះម៉ាក់យាយគិតថាចឹងម៉ាក់យាយគិតថាពេលណាដែរម៉ាក់យាយគិតថាសប្បាយនៅក្នុងជីវិតរបស់ ម៉ាក់យាយវិញទៅម៉ាក់យាយ?

ខ៖ មកឥឡូវនឹងនេះដឹងធូរបានដឹងថាសប្បាយនៅពេលនេះ

ក៖ អូ៎!!ប៉ុន្តែដូចជាការកូន រឺមួយក៏ការខ្លួនឯង?

ខ៖ នឹងហើយ

ក៖ រឺមួយក៏ជួបជុំកូនចៅដែរធ្វើអោយម៉ាក់យាយសប្បាយមែនទេ?

ខ៖ នឹងហើយការកូនការអីនឹងហាសដែរសប្បាយ

ក៖ អូ!!បាទម៉ាក់យាយបាទ ចុះម៉ាក់យាយកាលពីក្មេងម៉ាក់យាយធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងម៉ាក់យាយមានក្តីស្រម៉ៃថាម៉ាក់យាយចង់ធ្វើអីដែរទេ?

ខ៖ អត់ទេក្មួយគ្មានក្តីស្រម៉ៃថាចង់ធ្វើអីទេក្តីស្រម៉ៃធ្វើស្រែនឹង

ក៖ ប៉ុន្តែម៉ាក់យាយមានធ្លាប់ចង់ធ្វើជាគ្រូបង្រៀនធ្វើគ្រូពេទ្យ?

ខ៖ អត់ទេ

ក៖ រឺធ្វើប៉ូលីសអីទេ?

ខ៖ អត់

ក៖ អត់មានដែរគិតប៉ង់ប្រាថ្នាអីទេណាម៉ាក់យាយ?

ខ៖ អត់ទេ

ក៖ អូ៎!!បាទ ចុះបើសិនជាចង់អោយម៉ាក់យាយផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗៗនឹងតើម៉ាក់យាយចង់ផ្តែផ្តាំអីទៅពួកគាត់ដែរម៉ាក់យាយ?

ខ៖
គ្រាន់តែផ្តែផ្តាំអោយកូនចៅជំនាន់ក្រោយនឹងអោយខំប្រឹងគិតគូរធ្វើការធ្វើងាររកស៊ីអីនឹងគេកុំអោយ ខ្ជិលច្រអូសថ្នាំញៀនថ្នាំអីចឹងហាសក្មួយ

ក៖ អូ៎!!បាទម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖ ចុះម៉ាក់យាយមានចង់ផ្តែផ្តាំអោយពួកគាត់ធ្វើអីផ្សេងទៀតទេ?

ខ៖ ចា៎!!អត់ទេ

ក៖
ចង់អោយពួកគាត់ខំប្រឹងរៀនសូត្រមានការងារល្អអីចឹងហាសដើម្បីតាមគោលបំណងតាមដែរ ម៉ាក់យាយមានប៉ង់ប្រាថ្នាអីចឹងហាស?

ខ៖ នឹងហើយបើកូនវាធំៗៗអស់ហើយវាមានតូចៗៗណាមក

ក៖ ប៉ុន្តែពួកគាត់មានគ្រួសារអស់ហើយកូនរបស់ម៉ាក់យាយបាស?

ខ៖ មានអស់ហើយ

ក៖ អូ្វ!!ចឹងមានន័យថាម៉ាក់យាយមានចៅច្រើនហើយចឹង

ខ៖ ខ្ញុំមានចៅប្រហែលជាមាន3-4នាក់ដែរនឹងហាស

ក៖ អូ្វ!!ប៉ុន្តែកូនចៅរបស់ម៉ាក់យាយមានរស់នៅណាដែរទៅចឹង?

ខ៖ រស់នៅនឹងរស់នៅក្នុងភូមិនឹង

ក៖ ប៉ុន្តែគ្រាន់តែថាពួកគាត់រស់នៅបែកពីម៉ាក់យាយអស់ហើយ?

ខ៖ នឹងហើយរស់នៅបែកពីខ្ញុំអស់ហើយ

ក៖ ប៉ុន្តែម៉ាក់យាយរាល់ថ្ងៃនៅម្នាក់ឯងមែន?

ខ៖ រាល់ថ្ងៃខ្ញុំនៅជាមួយចៅចិញ្ចឹមចៅ

ក៖ អូ្វ!!បាទចឹងលុយកាក់អីពួកគាត់ផ្តល់អោយមក?

ខ៖ ចា៎!!

ក៖ អូ្វ!!ល្អចឹងម៉ាក់យាយមានអីផ្សេងទៀតទេម៉ាក់យាយ?

ខ៖ អត់ផងក្មួយមិនដឹងថាមានអីទៀតទេ

ក៖
បាទ!!ចឹងជាចុងក្រោយខ្ញុំអរគុណម៉ាក់យាយដែរបានអោយខ្ញុំបានពិភាក្សាពីប្រវត្តិរបស់ម៉ាក់យាយ ហើយខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នេះទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយម៉ាក់យាយនៅពេលក្រោយចឹងហាសម៉ាក់យាយ?

ខ៖ ចា៎!!

ក៖ បាទ!!ចឹងខ្ញុំអរគុណច្រើនម៉ាក់យាយ៕៕៕